អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

# អនុស្សរណៈអន្តរការិយាល័យ

**ពី៖** ឯកឧត្តម គង់ ស្រីម
ប្រធាន អង្គជំនុំជម្រះតុលាការកំពូល

កាលបរិច្ឆេទ៖ ៣០ ខែសីហា ឆ្នាំ២០២៤

**ទៅកាន់៖** ការិយាល័យសហព្រះរាជអាជ្ញា
ផ្នែកគាំពារការការពារក្តី
សហមេធាវីការពារក្តី មាស មុត
ផ្នែកគាំពារជនរងគ្រោះ
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ផ្នែកគ្រប់គ្រងតុលាការ
ប្រធាន និងអនុប្រធានរដ្ឋបាល

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-Aug-2024, 15:43
CMS/CFO: Sann Rada

**កម្មវត្ថុ៖** ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារក្នុងសំណុំរឿង ០០៣

១. អនុលោមតាមមាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (វិសោធនកម្មលើកទី២) អង្គជំនុំជម្រះតុលាការកំពូល ដែលជាការិយាល័យតុលាការចុងក្រោយ ដែលត្រូវបានប្តឹងអំពីសំណុំរឿង ០០៣/០៨-១០-២០២១-អ.វ.ត.ក./អ.ជ.ត.ក.(០៥) (“សំណុំរឿង ០០៣) តម្រូវឱ្យធ្វើការពិនិត្យឡើងវិញចំពោះឯកសារស្តីអំពីសុវត្ថិភាពនៃ

ការដាក់ចំណាត់ថ្នាក់ឯកសារសម្ងាត់ និងសម្ងាត់បំផុត ដែលបានដាក់នៅក្នុងនេះ ក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ឡើងវិញ ចំពោះឯកសារទាំងនោះឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ទៅកាន់សាធារណជន ដោយមាន ឬដោយមិនមានការកោសលុប តាមការចាំបាច់។

២. អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ក្នុងចំណោមឯកសារចំនួន ២៤.៤៤៧ ដែលបានដាក់ក្នុងសំណុំរឿង ០០៣ ឯកសារចំនួន ២២.០៣៣ ត្រូវបានចាត់ថ្នាក់ថាជាឯកសារ “សម្ងាត់” និង ៩៤ ជាឯកសារ “សម្ងាត់បំផុត” ដោយនៅសល់ឯកសារចំនួនតែ ២.៣២០ ប៉ុណ្ណោះ សម្រាប់សាធារណជនអាចចូលមើលបានបច្ចុប្បន្ននេះ។ ដោយកត់សម្គាល់ថា សំណុំរឿង ០០៣ ត្រូវបានបញ្ចប់ដោយមិនមានការជំនុំជម្រះ[1] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វាជាឱកាសមួយក្នុងការស្នើសុំមតិយោបល់ទាក់ទងនឹងភាពចាំបាច់ក្នុងការបន្តរក្សាការសម្ងាត់កំណត់ត្រាទាំងនេះក្នុងដំណាក់កាលបច្ចុប្បន្ននៃរឿងក្ដីនេះ។ ដូច្នេះ គោលបំណងនៃអនុស្សរណៈនេះ គឺដើម្បីស្វែងរកមតិយោបល់ពីភាគី ផ្នែក និង/ឬ អង្គភាពពាក់ព័ន្ធ នៅក្នុងដំណើរការនៃការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ សម្រាប់សំណុំរឿង ០០៣។

៣. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ខ្លួនបានបញ្ចប់ការពិនិត្យឡើងវិញស្រដៀងគ្នានេះសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញនូវឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០១, ០០២ និង ០០៤/០២[2]។ ឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៤ និង ០០៤/០១ ត្រូវបានពិនិត្យឡើងវិញដើម្បីធ្វើចំណាត់ថ្នាក់ឡើងវិញ ដោយអង្គបុរេជំនុំជម្រះ[3]។ ក្នុងការធ្វើការពិនិត្យឡើងវិញរបស់ខ្លួន អង្គជំនុំជម្រះ

[1] *សូមមើល* សំណុំរឿង ០០៣ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. ឯកសារ 3/1/1/1 ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។ *សូមមើលផងដែរ* សំណុំរឿង ០០៣ សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំឱ្យបញ្ចប់សំណុំរឿង ០០៣ ឯកសារ 4/1/1/1 ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១។

[2] *សូមមើល* សំណុំរឿង ០០១ សេចក្ដីសម្រេចធ្វើចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ឯកសារ F30/4 ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២។ សំណុំរឿង ០០២ ដីកាបង្គាប់ឱ្យអង្គភាពបណ្ណសារធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ឯកសារ F71/1/1/9 ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣។ សំណុំរឿង ០០៤/០២ ដីកាបង្គាប់ឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៤/០២ ឯកសារ E004/2/7/2 ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤។

[3] *សូមមើលផងដែរ* សំណុំរឿង ០០៤ អនុស្សរណៈអន្តរការិយាល័យនៃអង្គបុរេជំនុំជម្រះស្ដីពី ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤ ឯកសារ D387 ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។ សំណុំរឿង ០០៤/០១ អនុស្សរណៈអន្តរការិយាល័យនៃអង្គបុរេជំនុំជម្រះស្ដីពី ការចាត់ចំណាត់ថ្នាក់ឡើងវិញនៃឯកសារនៅក្នុងសំណុំរឿង ០០៤/០១ ឯកសារ D317 ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។

តុលាការកំពូលបានអនុម័តគោលការណ៍ណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ នៅក្នុងរឿងក្តីនីមួយៗ បន្ទាប់ពីទទួលបានមតិយោបល់ពី ភាគី ផ្នែក និង/ឬ អង្គភាពពាក់ព័ន្ធមួយ ឬច្រើន[4]។

៤. ដោយសារតែគោលការណ៍ណែនាំដែលត្រូវបានអនុម័ត នៅក្នុងរឿងក្តីទាំងអស់ ភាគច្រើនមានលក្ខណៈដូចគ្នា អង្គជំនុំជម្រះតុលាការកំពូលមានបំណងអនុម័តគោលការណ៍ណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ដូចគ្នានឹងការអនុម័តក្នុងសំណុំរឿង ០០២ ដូចដែលខ្លួនបានធ្វើក្នុងសំណុំរឿង ០០៤/០២ ដែរ[5]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភាគី ផ្នែក និង/ឬអង្គភាព ពាក់ព័ន្ធ គប្បីមានឱកាសបញ្ចេញយោបល់លើគោលការណ៍ណែនាំទាំងនោះ មុនពេលអង្គជំនុំជម្រះតុលាការកំពូលអនុម័តក្នុងសំណុំរឿង ០០៣។

៥. អង្គជំនុំជម្រះតុលាការកំពូល អញ្ជើញជាពិសេសឱ្យដាក់មតិយោបល់ដែលពាក់ព័ន្ធជាក់លាក់ទៅនឹងសំណុំរឿង ០០៣ អំពី (i) គោលការណ៍ណែនាំជាក់លាក់ណាមួយដែលខ្លួនគប្បីពិចារណាដាក់បន្ថែម ដកចេញ ឬកែប្រែ និង (ii) ឯកសារជាក់លាក់ណាមួយ និង/ឬ ក្រុម ឬប្រភេទឯកសារដែលខ្លួនគប្បីពិចារណាធ្វើចំណាត់ថ្នាក់ឡើងវិញ ដោយមាន ឬ ដោយមិនមានការកោសលុប។ សេចក្តីសង្កេតគប្បីផ្តោតលើបញ្ហាដែលបានគូសបញ្ជាក់ ដែលគួរតែពាក់ព័ន្ធជាក់លាក់ទៅនឹងសំណុំរឿង០០៣ និងការផ្តល់អនុសាសន៍អំពីវិធីដោះស្រាយបញ្ហាទាំងនោះ។ ប្រសិនបើអាចធ្វើទៅបាន សំណើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារជាក់លាក់ក្នុងសំណុំរឿង ០០៣ គប្បីត្រូវធ្វើឡើង។

៦. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល អញ្ជើញអ្នកដែលទទួលអនុស្សរណៈនេះ ដាក់សេចក្តីសង្កេតរបស់ខ្លួន ប្រសិនបើមាន លើ (i) ការអនុម័តក្នុងសំណុំរឿង ០០៣ នូវគោលការណ៍ណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ដូចដែលមានចែងក្នុងសំណុំរឿង ០០២ និង (ii) ការបន្តរក្សាភាពសម្ងាត់នៃឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៣ ឱ្យបានត្រឹមថ្ងៃសុក្រ ទី៤ ខែ

---

[4] *សូមមើល* សំណុំរឿង ០០១ សេចក្តីសម្រេចលើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ០០១ ឯកសារ F30/2 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២។ សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ឯកសារ F71/1/1/8 ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣។ សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៤/២ (E004/2/7) ឯកសារ E004/2/7/1 ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣។

[5] *សូមមើល* សំណុំរឿង០០៤/០២ ដីកាបង្គាប់ឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៤/០២ ឯកសារ E004/2/7/2 ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ទំព័រ ៤។

តុលា ឆ្នាំ២០២៤។ មិនមានការអនុញ្ញាតផ្តល់ការពន្យារចិរវេលាបន្ថែមទេ ហើយក៏មិនអនុញ្ញាតឱ្យមានចម្លើយតបទៅនឹងសេចក្តីសង្កេតរបស់ភាគី ផ្នែក និង/ឬ អង្គភាព ផ្សេងនោះដែរ៕